# របាយការណ៍ឆមាសទី ១ ឆ្នាំ ២០១៦ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ

## I. ស្ថានភាពការងាររបស់មន្ទីរ ៖

### 1. ការិយាល័យ រដ្ឋបាល និងកិច្ចការទូទៅ ៖

❖ **ស្ថានភាពបុគ្គលិកមន្ត្រីរាជការក្នុងមន្ទីរ**

ការងារគ្រប់គ្រងនិងដឹកនាំមន្ទីរមានថ្នាក់ដឹកនាំចំនួន ៤ រូប (ប្រធានមន្ទីរ និងអនុប្រធានមន្ទីរ ០៣ រូប) និងមានការិយាល័យជំនាញចំនួន ១០ ការិយាល័យ ៖

១- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ

២- ការិយាល័យផែនការ-ស្ថិតិ

៣- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ

៤- ការិយាល័យបណ្តុះបណ្តាល និងស្រាវជ្រាវ

៥- ការិយាល័យអភិវឌ្ឍន៍សហគមន៍

៦- ការិយាល័យផ្គត់ផ្គង់ទឹកជនបទ

៧- ការិយាល័យថែទាំសុខភាពជនបទ

៨- ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

៩- ការិយាល័យផ្លូវជនបទ

១០- ការិយាល័យអភិវឌ្ឍន៍ជនជាតិដើមភាគតិច និងមានការិយាល័យអភិវឌ្ឍន៍ជនបទស្រុកចំនួន ០៧ និងក្រុងចំនួន ០១។

#### 1.1. ចំនួនមន្ត្រីរាជការ

| | |
|---|---|
| – សរុប | ៖ ១៨នាក់ |
| – ប្រុស | ៖ ១៤នាក់ |
| – ស្រី | ៖ ០៤នាក់ |
| – ចំនួនប្រពន្ធមន្ត្រីរាជការ | ៖ ០៩ នាក់ |
| – ចំនួនកូន | ៖ ១៩ នាក់ |
| – អវត្តមាន | ៖ គ្មាន |
| – ចំនួនមន្ត្រីរាជការដែលស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស | ៖ គ្មាន |
| – ចំនួនមន្ត្រីរាជការផ្ទេរចូល | ៖ គ្មាន |
| – ចំនួនមន្ត្រីរាជការផ្ទេរចេញ | ៖ គ្មាន |
| – ចំនួនមន្ត្រីរាជការក្របខ័ណ្ឌថ្មី | ៖ គ្មាន |
| – ចំនួនមន្ត្រីរាជការបានតំឡើងប្រាក់បំណាច់មុខងារ | ៖ គ្មាន |

– ចំនួនមន្ត្រីរាជការបានតំឡើងឋានៈ ÷ គ្មាន
– ចំនួនមន្ត្រីរាជការចូលនិវត្តន៍ ÷ គ្មាន
– ចំនួនបុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលិកបណ្ដែត ÷ ២នាក់
– ចំនួនមន្ត្រីរាជការដែលទៅបំពេញបេសកកម្មនៅបរទេស ÷ គ្មាន
– ចំនួនមន្ត្រីរាជការសហការជាមួយកម្មវិធី និងជាដៃគូអង្គការនានា ÷ ៥នាក់

| ល.រ | នាម និងគោត្តនាម | ភេទ | មុខងារ | សហការជាមួយអង្គការ ឬកម្មវិធី |
|---|---|---|---|---|
| ១ | សេង សារី | ប | ប្រធានមន្ទីរ | -គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទានបន្ថែម (ADB)<br>- កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ២ | ម៉ប់ ធីរិត | ប | អនុប្រធានមន្ទីរ | កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៣ | ញាណ គង់ | ប | មន្ត្រី | - គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទាន បន្ថែម (ADB)<br>- កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៤ | ឆាយ សុវណ្ណា | ស | មន្ត្រី | កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៥ | គួន សកល | ប | មន្ត្រី | -កម្មវិធីកែលម្អហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចជនបទជំហានទី៣/៤ (RIP-III/RIPIV) |

### 1.2. ការងារលិខិតចេញ-ចូល

- ***បានធ្វើចរាចរលិខិតស្នាមក្នុងនោះមាន.***
  – មន្ទីរបានចេញលិខិតបេសកកម្មចំនួន ÷ ៥៥ច្បាប់
  – មន្ទីរបានចេញលិខិតទៅស្ថាប័ននានា និងក្នុងមន្ទីរចំនួន ÷ ១០០ច្បាប់
  – បានទទួលលិខិតចូលពីគ្រប់ស្ថាប័ននានា ចំនួន ÷ ១៤៥ច្បាប់
  – លិខិតផ្សេងៗចំនួន ÷ ០០ច្បាប់

### 1.3. ការងាររដ្ឋបាល និងបុគ្គលិក

– បានរៀបលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកផ្សេងៗជូនមន្ត្រីរាជការចេញដោយមន្ទីរចំនួន ៥ច្បាប់
– បានចូលរួមប្រជុំក្រៅខេត្តចំនួន ÷៣៧លើក
– បានចូលរួមប្រជុំក្នុងខេត្តចំនួន ÷៧៣លើក
– បានចូលរួមប្រជុំផ្ទៃក្នុងមន្ទីរចំនួន ÷០៦លើក

1.4. **ការងារបៀវត្ស និងពលកម្ម**

- បើកប្រាក់បៀវត្សប្រចាំខែជូនមន្ត្រីរាជការក្នុងអង្គភាព
- បើកប្រាក់ឧបត្ថម្ភជូនដល់មន្ត្រីរាជការចូលនិវត្តន៍
- ធ្វើរបាយការណ៍ប្រែប្រួលទៅមន្ទីរមុខងារសាធារណៈខេត្តព្រះវិហារ
- សំណើសុំបញ្ចូលអនុប្រធានការិយាល័យចំនួន០៤រូបចូលទៅក្នុងតារាងបៀវត្ស ក្នុងខែមីនាឆ្នាំ២០១៦
- បើកប្រាក់ឧបត្ថម្ភជូនមន្ត្រីរាជការដែលសុំលាឈប់
- ស្នើសុំនិយ័តកម្មប្រភេទក្របខណ្ឌប្រចាំឆ្នាំ២០១៦
- ចូលរួមប្រជុំស្តីពីក្របខណ្ឌមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា ឆ្នាំ២០១៦ នៅ មន្ទីរ មុខងារសាធារណៈ
- ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៦ ចូលរួមប្រជុំនៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ការរៀបចំបញ្ជីរាយនាមមន្ត្រីរាជការដែលត្រូវតម្លើងថ្នាក់ឆ្នាំ២០១៦
- ការរៀបចំជ្រើសរើសមន្ត្រីរាជការក្របខ័ណ្ឌឆ្នាំ២០១៦
- បើកប្រាក់បេសកម្មត្រីមាសទី៤ ឆ្នាំ២០១៥ ជូនមន្ត្រីរាជការ
- ការគ្រប់គ្រងបញ្ជីវត្តមានប្រចាំថ្ងៃ
- បញ្ហាផ្សេងៗ

2. **ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ**

+ **ប្រភពថវិការដ្ឋផ្តល់**

  - **ថវិកាអនុម័តឆ្នាំ២០១៦** ចំនួន ៥២៣,៥០០,០០០៛០០
    - ប្រាក់ជំពូក ៦០ ចំនួន ៧០,០០០,០០០៛
    - ប្រាក់ជំពូក ៦១ ចំនួន ១៧១,៥០០,០០០៛
    - ប្រាក់ជំពូក ៦៤ ចំនួន ២៨១,០០០,០០០៛
    - ប្រាក់ជំពូក ៦៣ ចំនួន ១,០០០,០០០៛
  - **ថវិកាចំណាយសម្រាប់ឆមាសទី ១ ឆ្នាំ២០១៦** ចំនួន ១៥១,០៩១,៨០០៛០០
    - ប្រាក់ជំពូក ៦០ គ្មាន
    - ប្រាក់ជំពូក ៦១ ចំនួន ២៦,៤១០,០០០៛០០
    - ប្រាក់ជំពូក ៦៤ ចំនួន ១២៤,៦៨១,៨០០៛០០
    - ប្រាក់ជំពូក ៦៣ គ្មាន

3. **ការងារផែនការ និងស្ថិតិ ÷**

- នៅថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០១៥ ចូលរួមក្នុងកិច្ចប្រជុំ ស្តីពីការរៀបចំកម្មវិធីវិនិយោគ បីឆ្នាំរំកិលរបស់រដ្ឋបាល ខេត្ត នៅសាលប្រជុំសាលាខេត្តព្រះវិហារ ។
- នៅថ្ងៃទី ២៨-៣១ ខែធ្នូ ឆ្នាំ ២០១៥ រៀបចំ និងធ្វើសៀវភៅផែនការថវិកាកម្មវិធីឆ្នាំ ២០១៦ ផ្ញើទៅនាយក ដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ នៃក្រសួង អភិវឌ្ឍន៍ជនបទ ។
- នៅថ្ងៃទី ១១-១៣ ខែមករា ឆ្នាំ២០១៦ រៀបចំ និងធ្វើសៀវភៅផែនការវិនិយោគបីឆ្នាំរំកិល ខេត្ត (២០១៦-២០១៨) ផ្ញើទៅមន្ទីរផែនការខេត្ត និងសាលាខេត្ត។
- នៅថ្ងៃទី ០៣-១២ ខែកុម្ភៈ ឆ្នាំ២០១៦ រៀបចំ និងធ្វើសៀវភៅផែនការថវិកាកម្មវិធីឆ្នាំ ២០១៦ ។
- នៅថ្ងៃទី ២២-២៤ ខែកុម្ភៈ ឆ្នាំ២០១៦ ចូលរួមសន្និបាតបូកសរុបការងារឆ្នាំ២០១៥ និង ទិសដៅការងារ ឆ្នាំ២០១៦ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅរាជធានីភ្នំពេញ
- នៅថ្ងៃទី ០១-០៤ ខែមីនា ឆ្នាំ២០១៦ រៀបចំ និងធ្វើសៀវភៅផែនការថវិកាកម្មវិធីឆ្នាំ ២០១៦ ផ្ញើទៅនាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ ។
- ថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០១៦ ធ្វើរបាយការណ៍ប្រចាំខែមីនា ផ្ញើទៅនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
- ថ្ងៃទី ៣១ មីនា ដល់ ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ចូលរួមក្នុងដំណើរទស្សនកិច្ចរបស់ យុវជន ក្រសួង អភិវឌ្ឍន៍ជនបទ ដើម្បីស្វែងយល់ពីការងារអភិវឌ្ឍន៍ជនបទនៅតាម បណ្តោយព្រំដែនកម្ពុជា-ថៃ ក្នុងខេត្ត ព្រះវិហារ។
- ថ្ងៃទី ០៨ ខែមេសា ឆ្នាំ ២០១៦ ចូលរួមប្រជុំក្នុងការផ្សព្វផ្សាយអនុក្រឹត្យស្តីពីការគ្រប់គ្រង វត្តមាន មន្ត្រី រាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា នៅក្នុងមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តព្រះវិហារ។
- ថ្ងៃទី ២១-២២-២៥ ខែមេសា ឆ្នាំ ២០១៦ ធ្វើរបាយការណ៍វឌ្ឍនៈភាពត្រីមាសទី១ ឆ្នាំ ២០១៦ ផ្ញើទៅនាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ។
- ថ្ងៃទី ២៥-២៦ ខែមេសា ឆ្នាំ២០១៦ រៀបចំគ្រោងថវិកាឆ្នាំ២០១៧ និងធ្វើផែនការថវិកា យុទ្ធសាស្ត្រ ឆ្នាំ២០១៧-២០១៩។
- ថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១៦ ចូលរួមប្រជុំការផ្សព្វផ្សាយសារាចរណែនាំលេខ០១ សរណន ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៧ នៅសាលប្រជុំមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តព្រះវិហារ។

- ថ្ងៃទី ០៨-០៩ ខែមិថុនា ឆ្នាំ ២០១៦ ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីលទ្ធផលនៃការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០១៧-២០១៩ និងការរៀបចំផែនការថវិកាកម្មវិធី សម្រាប់ឆ្នាំ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព ឯកឧត្តម សៅ ជីវ៉ន រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន រដ្ឋមន្រ្តីក្រសួងអភិវឌ្ឍន៍ជនបទ និងមានការចូលរួមពីមន្រ្តីរាជការទាំង២៥ រាជធានី-ខេត្ត នៅសណ្ឋាគារខេមរា ខេត្តបាត់ដំបង។

4. **ការងារអធិការកិច្ច និង សវនកម្ម÷**
   - ថ្ងៃទី ២៨-២៩ ខែកុម្ភៈ ឆ្នាំ២០១៦ បានចូលរួមក្នុងកិច្ចសនវនកម្មថ្នាក់ជាតិចុះត្រួតពិនិត្យចំណូល-ចំណាយ ថវិការដ្ឋឆ្នាំ២០១៥ របស់សវនកម្មជាតិ។
   - ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៦ ចូលរួមប្រជុំជាមួយប្រតិភូរសវនកម្មផ្ទៃក្នុងនៃក្រសួងអភិវឌ្ឍន៍ជនបទ នៅសាលប្រជុំមន្ទីរអភិវឌ្ឍន៍ជនបខេត្តព្រះវិហារ ដឹកនាំដោយលោក ពេជ្យ ស៊ីថា ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង និងមានការចូលរួមពីមន្ត្រីរាជការនៃមន្ទីរអភិវឌ្ឍន៍ទាំងអស់។

5. **ការងារទំនាក់ទំនងសាធារណ**:
   - ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥ លោកអនុប្រធានមន្ទីរ និងជាសមាជិកលេខាធិការដ្ឋានគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត បានចូលរួមក្នុងសម័យប្រជុំគណបញ្ជាការឯកភាពរដ្ឋបាលខេត្ត ក្រោមអធិបតីភាព**ឯកឧត្តម អ៊ុំ ម៉ារ៉ា** អភិបាល នៃគណអភិបាលខេត្ត និងជាប្រធានអង្គប្រជុំ។
   - បានចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ២០១៥-២០១៦ ជាមួយអង្គការដៃគូ នៅខេត្តព្រះសីហនុ។
   - ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ ចូលរួមប្រជុំរៀបចំរបាយការណ៍ស្តីពីការអនុវត្តគម្រោងក្រុង-ស្រុក ឃុំ-សង្កាត់ ឆ្នាំ២០១១៥ ក្រោមអធិបភាព ឯកឧត្តម អ៊ុន ចាន់ដា អភិបាលរងនៃគណៈអភិបាលខេត្តព្រះវិហារ ,អភិបាល ក្រុង-ស្រុក ,មេឃុំ-ចៅសង្កាត់ និងបណ្តាមន្ទីរអង្គភាពពាក់ព័ន្ធ នៅសាលប្រជុំជាន់ទី៣ សាលា ខេត្តព្រះវិហារ។
   - ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ ចូលរួមសម្ពោធដាក់អោយប្រើប្រាស់ស្ពានបេតុងប្រវែង ៧២ម៉ែត្រ នៅអូររំដួល ឃុំតស៊ូ ស្រុកជ័យសែន និងបើកការដ្ឋានសាងសង់ស្ពានបេតុង ០១កន្លែង ទៀតប្រវែង ១៤៤ម៉ែត្រ ក្រោម អធិបតីដ៏ខ្ពង់ខ្ពស់ ឯកឧត្តម មាស សុភា ប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តព្រះវិហារ។
   - ថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០១៦ ចូលរួមក្នុងពិធីចែកវិញ្ញាប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ នៃកម្មវិធីសម្បទានដី សង្គមកិច្ចជូនយោធិន និងគ្រួសារ ដែលកំពុងឈរជើងការពារ

បូរណភាពទឹកដីទិសខាងលិច និងខាងជើងនៃ ព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ នៅភូមិរុងរឿង១ ឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។

- ថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១៦ ចូលរួមទិវាវប្បធម៌ជាតិ ៣មីនា លើកទី១៨ ឆ្នាំ២០១៦ ក្រោមប្រធានបទ (យុវជនដើម្បីវប្បធម៌ជាតិ) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ នៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តព្រះវិហារ។
- ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ចូលរួមប្រជុំពិភាក្សាការងាររបស់អនុគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោក ខេត្តព្រះវិហារក្រោមអធិបតីភាព ឯកឧត្តម ស៊ូ សិរី អភិបាលរងនៃគណៈអភិបាលខេត្តព្រះវិហារ នៅសាល ប្រជុំ Video Conference អាគាររដ្ឋបាលសាលាខេត្តជាន់ទី១។
- រសៀលថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ចូលរួមប្រជុំពិភាក្សាការងារស្តីអំពីការចុះសម្របសម្រួលវិវាទដីធ្លីរបស់ ប្រជាពលរដ្ឋនៅឃុំប្រមេរ ស្រុកត្បែងមានជ័យ ក្រោមអធិបតីភាព **ឯកឧត្តម សុខ ហៃ** អភិបាលរងនៃ គណអភិបាលខេត្តព្រះវិហារ នៅសាល ប្រជុំ Video Conference អាគាររដ្ឋបាលសាលាខេត្តជាន់ទី១។
- ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ចូលរួមប្រជុំពិភាក្សាពិនិត្យទីតាំងសម្រាប់ពិធីសម្ពោធរោងចក្រផលិតស្ករអំពៅនា ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពង់ **សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា។
- ព្រឹកថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ចូលរួមសម្ពោធរោងចក្រផលិតស្ករអំពៅ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពង់ **សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។
- រសៀលថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ចូលរួមជាមួយឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ** ចុះពិនិត្យសមិទ្ធិផលដែលបានអនុវត្តកន្លងមក និងកំពុងអនុវត្តនៅតាមបណ្តោយព្រំដែន កម្ពុជា-ថៃ និងបាន ជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំមន្ទីរមន្ត្រីរាជការក្រោមឱវាទមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ។
- នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៦ ចូលរួមក្នុងកិច្ចប្រជុំសាមញ្ញ លើកទី២៣ របស់ក្រុមប្រឹក្សាខេត្ត អាណត្តិទី២ ក្រោមអធិបតីភាព ឯកឧត្តម ឡុង សុវណ្ណ ប្រធានក្រុមប្រឹក្សាខេត្ត នៅសាលប្រជុំសាលា ខេត្តព្រះវិហារ។

- នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៦ ចូលរួមប្រជុំពិភាក្សាពីការរៀបចំកិច្ចសន្យាស្តីពីការផ្តល់អចលនវត្ថុ រវាងសាខាកាកបាទក្រហមកម្ពុជាខេត្តព្រះវិហារ និងសាខាកាកបាទក្រហមកម្ពុជារាជធានីភ្នំពេញ ក្រោម អធិបតីភាព លោកជំទាវ ចឹក ហេង ប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមខេត្តព្រះវិហារ នៅសាលប្រជុំសាខាកាកបាទក្រហមកម្ពុជាខេត្តព្រះវិហារ។
- នៅថ្ងៃទី ០២ ខែឧសភា ឆ្នាំ ២០១៦ ចូលរួមប្រជុំពិភាក្សាត្រៀមផែនការការពារសន្តិសុខព្រះរាជវត្តមានព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថនរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម អ៊ុំ ម៉ារ៉ា អភិបាលនៃគណៈអភិបាលខេត្ត នៅសាលប្រជុំសាលាខេត្តព្រះវិហារ។
- នៅថ្ងៃទី ០២ ខែឧសភា ឆ្នាំ ២០១៦ ចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវក្រាលកៅស៊ូ ប្រភេទ DBST ប្រវែង៣៧០ម៉ែត្រ និងបើកការដ្ឋានជួសជុលពង្រីកសងខាងផ្លូវម្លូព្រៃប្រវែង ២,១៧០ម៉ែត្រ ស្ថិតនៅក្នុងក្រុងព្រះវិហារ ខេត្តព្រះវិហារ ក្រោមអធិបតីភាព ឯកឧត្តម អ៊ុំ ម៉ារ៉ា អភិបាលនៃគណៈអភិបាល ខេត្ត ដែលប្រព្រឹត្តទៅនៅក្នុងមជ្ឈមណ្ឌលកុមារកំព្រា។
- នៅថ្ងៃទី ១១-១២ ខែឧសភា ឆ្នាំ ២០១៦ បានចូលរួមក្នុងពិធីសូត្រមន្ត និងពិធីប្រគល់-ទទួលអដ្ឋិធាតុ កងទ័ពស្ម័គ្រចិត្តវៀតណាម ទៅទីរួមខេត្តព្រះវិហារ។
- ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៦ ចូលរួមសិក្ខាសាលាថ្នាក់ខេត្ត ស្តីពីការផ្សព្វផ្សាយដំណើរការបច្ចុប្បន្នកម្ម ទិន្នន័យគ្រួសារក្រីក្រឆ្នាំ២០១៦ ក្រោមអធិបតីភាព ឯកឧត្តម មាស រដ្ឋាវុឌ្ឍ សមាជិកក្រុមប្រឹក្សាខេត្ត ព្រះវិហារ នៅសាលប្រជុំជាន់ទី ៣ សាលាខេត្តព្រះវិហារ។
- ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៦ បានចូលរួមប្រជុំការងារបច្ចេកទេសសុខាភិបាលខេត្ត នៅមន្ទីរសុខាភិបាលខេត្តព្រះវិហារ ដែលមានអ្នកចូលរួមសរុប ១៧នាក់ ក្នុងនោះស្រី ៨នាក់។

## II. សកម្មភាពការងារតាមវិស័យ ÷

### 1. សកម្មភាពផ្លូវជនបទ

- ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០១៦ ចុះធ្វើបច្ចុប្បន្នភាពរៀបចំបញ្ជីសារពើភ័ណ្ឌ និងទិន្នន័យផ្លូវជនបទនៅស្រុកជ័យសែន ។
- ថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០១៦ ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៥ និងទិសដៅការងារ ឆ្នាំ២០១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី** និងជាប្រធានក្រុមប្រឹក្សា ស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ តំណាងដ៏ខ្ពង់

ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលចតុមុខ រាជធានីភ្នំពេញ។

- ថ្ងៃទី ០៦-០៧ ខែឧសភា ឆ្នាំ ២០១៦ ចុះសិក្សាផ្លូវចំនួន០១ខ្សែប្រវែងសរុប៧៤០០ម៉ែត្រ ស្ថិតនៅ ភូមិអូរកក់ទៅភូមិក្រឡាពាស ឃុំព្រីងធំ ស្រុកជាំក្សាន្ត។
- ថ្ងៃទី ០៩-១០ ខែឧសភា ឆ្នាំ ២០១៦ រៀបចំធ្វើឯកសារ និងគូសផែនទីទីតាំងផ្លូវដែលមានចំណុចចាប់ផ្តើមចេញពីភូមិអូរកក់ ទៅភូមិក្រឡាពាស ឃុំព្រីងធំ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។
- ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៦ ចុះពិនិត្យស្ថានភាពកំណាត់ផ្លូវប្រវែង២៣០០ម៉ែត្រ ស្ថិតនៅ ភូមិប្រាច់ ឃុំប្រាច់ ស្រុកជ័យសែន ខេត្តព្រះវិហារ ដែលការចូលរួមជាលក្ខណៈអន្តរក្រសួងរួមមាន តំណាងក្រសួង អភិវឌ្ឍន៍ជនបទ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតំណាងក្រសួងអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ។
- ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១៦ រៀបចំធ្វើឯកសារ និងធ្វើកំណត់ហេតុ ស្តីពីការចុះពិនិត្យស្ថានភាពផ្លូវ ប្រវែង២៣០០ម៉ែត្រ ស្ថិតនៅភូមិប្រាច់ ឃុំប្រាច់ ស្រុកជ័យសែន ខេត្តព្រះវិហារ ផ្ញើទៅនាយកដ្ឋានផ្លូវលំជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ ។
- ថ្ងៃទី ២៣-២៤ ខែឧសភា ឆ្នាំ ២០១៦ ចុះត្រួតពិនិត្យការងារជួសជុល និងថែទាំផ្លូវជាលក្ខណៈខួប ប្រវែង ១៥ គីឡូម៉ែត្រ ស្ថិតនៅចំនុចចាប់ផ្តើមឃុំស្អាងរហូតដល់ឃុំប្រាច់ ស្រុកជ័យសែន ខេត្តព្រះវិហារ។
- ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៦ ចុះពិនិត្យស្ថានភាពកំណាត់ផ្លូវប្រវែង២៣០០ម៉ែត្រ ស្ថិតនៅភូមិប្រាច់ ឃុំប្រាច់ ស្រុកជ័យសែន ខេត្តព្រះវិហារ ដែលការ ចូលរួមជាលក្ខណៈអន្តរក្រសួងរួមមាន តំណាងក្រសួង អភិវឌ្ឍន៍ជនបទ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតំណាងក្រសួងអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ។
- ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១៦ រៀបចំធ្វើឯកសារ និងធ្វើកំណត់ហេតុ ស្តីពីការចុះពិនិត្យស្ថានភាពផ្លូវ ប្រវែង២៣០០ម៉ែត្រ ស្ថិតនៅភូមិប្រាច់ ឃុំប្រាច់ ស្រុកជ័យសែន ខេត្តព្រះវិហារ ផ្ញើទៅនាយកដ្ឋាន ផ្លូវលំជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ ។
- ថ្ងៃទី ២៣-២៤ ខែឧសភា ឆ្នាំ ២០១៦ ចុះត្រួតពិនិត្យការងារជួសជុល និងថែទាំផ្លូវជាលក្ខណៈខួប ប្រវែង១៥ គីឡូម៉ែត្រ ស្ថិតនៅចំនុចចាប់ផ្តើមឃុំស្អាងរហូតដល់ឃុំប្រាច់ ស្រុកជ័យសែន ខេត្តព្រះវិហារ។
- ថ្ងៃទី ៩-១០ ខែមិថុនា ឆ្នាំ ២០១៦ បានចុះត្រួតពិនិត្យផ្លូវថែទាំជាលក្ខណៈខួបប្រវែងសរុប ១៥០០០ ម៉ែត្រ ស្ថិតនៅស្រុកជ័យសែន ខេត្តព្រះវិហារ។

## 2. សកម្មភាពបញ្ជីសារពើភ័ណ្ឌផ្លូវជនបទ

### 2.1. ការចុះស្រង់ទិន្នន័យផ្លូវ

- នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៦ ក្រុមការងារថ្នាក់មន្ទីរបានចុះទៅមើលការដ្ឋានការងារបញ្ចប់សុពលភាព ផ្លូវថៃទាំខួបគម្រោងឆ្នាំ ២០១៥ សម្រេចលទ្ធផលបាន ១០០% ចំនួន ០១ខ្សែប្រវែង ១២.០០០ ម៉ែត្រស្ថិតនៅ ឃុំគូលែនត្បូង , ឃុំភ្នំពេញ និង ឃុំភ្នំត្បែងពីរ ស្រុកគូលែន ខេត្តព្រះវិហារ ។
- ទិន្នន័យផ្លូវជនបទទាំងបួនប្រភេទសរុបចំនួន ៤០៣ ខ្សែ ស្មើ ១,៣០៥.២០៦គម
- នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ ក្រុមការងារបានចុះស្រង់ទិន្នន័យផ្លូវជនបទបានចំនួន ០៥ខ្សែ ប្រវែង ១០.៤២៨ម៉ែត្រ លូគ្រប់ប្រភេទចំនួន ១៩ កន្លែង ស្ថិតនៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។
- ថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០១៦ ចូលរួមប្រជុំក្រុមការងាររៀបចំបញ្ជីសារពើភ័ណ្ឌ និង មូលដ្ឋានទិន្នន័យផ្លូវជន បទនៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ ។
- ថ្ងៃទី ០៨-០៩ ខែមេសា ឆ្នាំ២០១៦ ចុះត្រួតពិនិត្យ ណិងសិក្សាផ្លូវក្រាលគ្រួសក្រហម មួយ ខ្សែ ប្រវែង ២០គីឡូម៉ែត្រ ដែលត្រូវស្ថាបនាចេញពីផ្លូវជាតិលេខ ៦២ ត្រង់ចំនុចភូមិថ្មល់ កោងទៅកាន់ភូមិរំដោះ ។
- នៅថ្ងៃទី ១៨-២០ ខែឧសភា ឆ្នាំ ២០១៦ បានចុះស្រង់ទិន្នន័យផ្លូវប្រភេទលេខ ០៣ ចំនួន ០៤ខ្សែ ប្រវែង ៣៣ ៦០០ម៉ែត្រ លូគ្រប់ប្រភេទចំនួន៥០កន្លែង និងស្ពានបេតុងចំនួន ២៤កន្លែង។
- នៅថ្ងៃទី ១៨-២០ ខែឧសភា ឆ្នាំ ២០១៦ បានចុះស្រង់ទិន្នន័យផ្លូវប្រភេទលេខ ០៣ ចំនួន ០៤ខ្សែ ប្រវែង ៣៣ ៦០០ម៉ែត្រ លូគ្រប់ប្រភេទចំនួន៥០កន្លែង និងស្ពានបេតុងចំនួន ២៤កន្លែង។
- ថ្ងៃទី ១៨-២០ ខែឧសភា ឆ្នាំ ២០១៦ បានចុះស្រង់ទិន្នន័យផ្លូវប្រភេទលេខ០៣ ចំនួន ០៤ខ្សែ ប្រវែង ៣៣ ៦០០ម៉ែត្រ លូគ្រប់ប្រភេទចំនួន៥០កន្លែង និងស្ពានបេតុងចំនួន ២៤កន្លែង។

### 2.2. ការងារធ្វើបច្ចុប្បន្នភាព

- ថ្ងៃទី ២៧-២៨ ខែធ្នូ ឆ្នាំ២០១៥ ចុះធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌ និងមូលដ្ឋានផ្លូវ ជនបទ ពីភូមិរបុញ ទៅកាន់ ភូមិកំពង់ស្រឡៅឃុំកំពង់ស្រឡៅ១ ស្រុកឆែប បានចំនួន ១ខ្សែ ប្រវែង ៦៥,៩៨ គីឡូមែត្រ ។

- នៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៦ ក្រុមការងារបានចុះធ្វើបច្ចុប្បន្នភាព ស្រង់ទិន្នន័យផ្លូវជនបទ បានចំនួន០១ខ្សែប្រវែង ៣២.៤០០ម៉ែត្រ ស្ពានបេតុងចំនួន០១ កន្លែង និងលូគ្រប់ប្រភេទចំនួន១១ កន្លែង ស្ថិតនៅ ស្រុកត្បែងមានជ័យ ស្រុករវៀង និង ស្រុកជ័យសែន ខេត្តព្រះវិហារ។
- នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ ក្រុមការងារបានចុះធ្វើបច្ចុប្បន្នភាព ស្រង់ទិន្នន័យផ្លូវជនបទបានចំនួន ០២ខ្សែប្រវែង ៥៥.១០០ម៉ែត្រ ស្ពានចំនួន ១១ កន្លែង និងលូគ្រប់ប្រភេទចំនួន ៥៧ កន្លែង ស្ថិតនៅស្រុកជាំ ក្សាន្តខេត្តព្រះវិហារ ។

3. **ការងារផ្គត់ផ្គង់ទឹកជនបទ**

- បានលើកសំណើគម្រោងផែនការសកម្មភាពថវិកា ឆ្នាំ២០១៦ ដាក់ជូននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ
- ថ្ងៃទី ១០ ដល់ ១១ ខែ ធ្នូ ឆ្នាំ២០១៥ បានចូលរួមសម្របសម្រួលវគ្គបំប៉នគ្រូបង្គោលស្តីពីកម្មវិធី សហគមន៍ដឹ កនាំអនុវត្តន៍អនាម័យទាំងស្រុង នៅសាលាស្រុកសង្គមថ្មី ដែលមានអ្នកចូលរួមសរុបចំនួន ៧៩ នាក់ ស្រី ២៦ នាក់។
- ថ្ងៃទី ៣០ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៥ បានចូលរួមសម្របសម្រួលជួសជុលអណ្តូងស្នប់បាន ចំនួន ៣ អណ្តូង(អាហ្វ្រីដេវ=២អណ្តូងនៅភូមិ អូរស្មៀត និងភូមិស្លែង និង VN6=១អណ្តូង នៅម៉ឺនរាជ)។
- ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៦ បានសម្របសម្រួលការប្រជុំពិភាក្សាលើការងារអនាម័យ នៅសាលាស្រុក សង្គមថ្មី ដែលមានអ្នកចូលរួម ៤៥នាក់ ស្រី ១៩នាក់ ដែលគាំទ្រដោយអង្គការទស្សនពិភពលោកប្រចាំស្រុក សង្គថ្មី។
- ថ្ងៃទី ៥ -៦ ខែ មករា ឆ្នាំ ២០១៦ បានសម្របសម្រួលការចុះកំណត់ទីតាំងអណ្តូងបានសរុបចំនួន ១១ អណ្តូងក្នុងឃុំចំនួន ៤ឃុំ ស្រុកសង្គមថ្មី (ឃុំចម្រើន=១អណ្តូង, ឃុំ ស្ដៅ=៦អណ្តូង, ឃុំត្បែងមួយ =២អណ្តូង) និងឃុំរំដោះ ស្រុករវៀងបាន ២អណ្តូង ដែលគាំទ្រដោយអង្គការទស្សនពិភពលោកប្រចាំស្រុក សង្គមថ្មី។
- ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ បានចូលរួមសម្របសម្រួលការប្រជុំពិភាក្សាលើការងារអនាម័យជាមួយ គណកម្មាធិការអនាម័យឃុំសង្កែមួយ នៅសាលាបឋមសិក្សាស្រអែម មានអ្នកចូលរួម សរុបចំនួន ២១នាក់ ស្រី ០៨នាក់។
- ថ្ងៃទី ០២ ដល់០៨ ខែ កុម្ភៈ ឆ្នាំ២០១៦ បានចូលរួមសម្របសម្រួលស្តីពី ការបញ្ចាំងវីដេអូអប់រំអនាម័យដល់សហគមន៍ចំនួន ០៧ភូមិ ក្នុង ២ឃុំ (ឃុំចំរើនមានភូមិត្បែង, ភូមិប្រធាតុ, ភូមិដា និងឃុំរំដោះមានភូមិ ស្វាយប៉ាត, ភូមិថ្មល់កោង, ភូមិគោកអំពិល និងភូមិឪឡឹក) ដែល

មានអ្នកចូលរួមទស្សនាចំនួនសរុប ៨៥០ នាក់ស្រី ៥៦៧នាក់ និងក្មេងៗចំនួន ២៣២នាក់ ដែលគាំទ្រ ដោយអង្គការទស្សនពិភពលោកប្រចាំ ស្រុក សង្គមថ្មី។

- ថ្ងៃទី ០៨ ដល់ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៦ បានចូលរួមសម្របសម្រួលស្តីពីការចុះតំណត់ទីតាំងអណ្តូង ស្នប់អាហ្វ្រិដេវចំនួន ២៧អណ្តូងស្នប់ក្នុងឃុំចំនួន ៣ គឺ ឃុំម្លូព្រៃមួយ (មានភូមិពោធិ៍ទាប បាន ០៧អណ្តូង ភូមិកុល បាន០៤អណ្តូង និងភូមិម្លូព្រៃ បាន ០៣អណ្តូង) ឃុំម្លូព្រៃពីរ (មានភូមិប្រើសក្អែកបាន ០៤អណ្តូង និង បុស្សបាន ០២អណ្តូង) និងឃុំឆែបពីរ (ភូមិដងផ្លិតបាន ២ អណ្តូង, ភូមិប្រាបាន ៣អណ្តូង, និងភូមិគុណ ភាពបាន ២ភូមិ) ដែលគាំទ្រដោយអង្គការទស្សនៈ ពិភពលោកប្រចាំស្រុកឆែប។
- ថ្ងៃទី ១៦-១៧ ខែ កុម្ភៈ ឆ្នាំ ២០១៦ បានសម្របសម្រួលវគ្គស្តីពី ភាពជាសាលាគំរូផ្នែកទឹកស្អាត និងអនាម័យ ដល់នាយកសាលា លោកគ្រូអ្នកគ្រូ និងមណ្ឌលសុខភាព សរុបចំនួន ២៨នាក់ ស្រី ១៧នាក់នៅការិយាល័យ អង្គការទស្សនពិភពលោកប្រចាំស្រុកគូលែន។
- ថ្ងៃទី ១៨-២៧ ខែ កុម្ភៈ ឆ្នាំ ២០១៦ ក្រុមការងារមន្ទីរអភិវឌ្ឍន៍ចំនួន ០២រូប បានសហការជាមួយអង្គការទស្សនៈពិភពលោកប្រចាំស្រុកជ័យសែនចុះកំណត់ទីតាំងអណ្តូង និងយកនិយាមការបានចំនួនអណ្តូង ២៨អណ្តូងនៅឃុំស្អាងសរុបចំនួន ០៦អណ្តូង (ភូមិគោក=០៤អណ្តូង និងភូមិស្អាង=០២អណ្តូង) ឃុំ តស៊ូសរុបចំនួន ១១ អណ្តូង (ភូមិសំរោង= ០៤អណ្តូងភូមិទួលធ្នុង=០២អណ្តូង ភូមិទួលឈូក=០២អណ្តូង និងភូមិអូរស្មៀត=០៣អណ្តូង) ឃុំខ្យង សរុបចំនួន ០២អណ្តូង(ភូមិម៉ីនរាជ=០២អណ្តូង) និងឃុំពុទ្រាសរុបចំនួន ០៩អណ្តូង ០៧អណ្តូង (ភូមិពើក=០៥អណ្តូង ភូមិពុទ្រា=០២អណ្តូង ភូមិក្រវ៉ាន់=០២អណ្តូង)
- ថ្ងៃទី ១៤-២០ ខែ មីនា ឆ្នាំ ២០១៦ ក្រុមការងារមន្ទីរចំនួន ០២រូបបានសហការជាមួយអង្គការទស្សនៈពិភពលោកប្រចាំស្រុករវៀង ស្តីពីការចុះវាយតម្លៃ ភូមិចំនួន ០៥ ក្នុងឃុំចំនួន ០៣ (ឃុំរមទមមានភូមិភ្នំដែក, ឃុំរុង រៀងមានភូមិបុះពៃ និងភូមិរវៀងត្បូង និងឃុំរបៀបមានភូមិរវៀងជើង និងភូមិត្នោតម្លូរដើម្បី ក្លាយជាភូមិ បញ្ឈប់បន្ទោរបង់ពាសវាលពាសកាល។ ជាលទ្ធផលតាមការចុះវាយតម្លៃភូមិទាំង ០៥ នឹងអាចក្លាយជាភូមិបញ្ឈប់ពាសវាលពាសកាលក្នុងខែមីនានេះ។
- ថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ចូលរួមពិនិត្យ និងវាយតម្លៃនៃការធានាគុណភាពការសាងសង់ស្ថានីយចែកចាយទឹកស្អាត នៅភូមិពង្រ ឃុំថ្មី ស្រុកគូលែន ខេត្តព្រះវិហារ។
- ថ្ងៃទី ០៤ ដល់ ០៦ ខែមេសា ឆ្នាំ២០១៦ បានចូលរួមសម្របសម្រួលសិក្សាវាយតម្លៃអណ្តូងដែលចំនួន ០៩អណ្តូង (ក្នុងភូមិបង្កូន=០៤អណ្តូង, ភូមិស្រែ=០៣អណ្តូង និងភូមិស្លែងទួល=០២ណ្តូង) ក្នុងឃុំរៀបរយ ស្រុករវៀង ខេត្តព្រះវិហារ ជាលទ្ធផលអណ្តូងស្នប់អាចជួសជុល

បានមានចំនួន ០៨អណ្តូង ហើយ០១អណ្តូង ទៀត មិនអាចជួសជុលបានទេព្រោះខូចធ្ងន់ធ្ងរពេក។

- ថ្ងៃទី ១៨ ដល់ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០១៦ បានចូលរួមសម្របសម្រួលជួសជុលអណ្តូងស្នប់បានចំនួន ០៣អណ្តូង (អាហ្វ្រីដេវ=០២អណ្តូងនៅភូមិ ត្រពាំងទន្ទឹម និងភូមិបង្កើនផល =០១អណ្តូង)។
- នៅថ្ងៃទី ០២-០៦ ខែឧសភា ឆ្នាំ ២០១៦ បានចុះទំនាក់ទំនងជាមួយលោកមេឃុំ ទូទាំងក្រុង/ស្រុក ដើម្បីស្រង់ព័ត៌មានអណ្តូងរីកស្ងួតតាមបណ្តាក្រុង ស្រុក ឃុំ បានចំនួនចំនួន ៥១ ឃុំ ក្នុង០៨ក្រុង/ស្រុក រួចធ្វើជាផែនការដាក់ជូននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទរួចរាល់ហើយ។
- នៅថ្ងៃទី ១៧-២១ ខែឧសភា ឆ្នាំ ២០១៦ បានចុះពិនិត្យ និងជួសជុលអណ្តូងបានចំនួន ៣៦ អណ្តូង ដែលស្ថិតនៅក្នុង ១៤ភូមិ ០៦ឃុំ នៅស្រុកគូលែន។
- ថ្ងៃទី ១៧-២១ ខែឧសភា ឆ្នាំ ២០១៦ បានចុះពិនិត្យ និងជួសជុលអណ្តូងបានចំនួន ៣៦ អណ្តូង ដែលស្ថិតនៅក្នុង១៤ភូមិ ០៦ឃុំ នៅស្រុកគូលែន។
- ថ្ងៃទី ១-២ ខែមិថុនា ឆ្នាំ ២០១៦ បានជួសជុលអណ្តូងបានចំនួន ០២ អណ្តូង ដែលស្ថិតនៅភូមិត្រពាំងទន្ទឹម ឃុំ រមទម នៅស្រុករវៀង។
- ថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០១៦ បានរៀនចំរបាយការណ៍ពីស្ថានភាពអណ្តូងរីងស្ងួត និងលើកផែនការ នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទទៅក្រសួងអភិវឌ្ឍនជនបទ។
- ថ្ងៃទី ៧-១០ ខែមិថុនា ឆ្នាំ២០១៦ បានចូលរៀនវគ្គគ្រូបង្គោលស្តីពី កម្មវិធីសហគមន៍ដឹកនាំអនុវត្តអនាម័យ នៅសាលប្រជុំកបាតក្រហមប្រចាំខេត្តព្រះវិហារ។

4. **ការងារថែទាំសុខភាពជនបទ**

- បានចុះពិនិត្យអ្នកម៉ៅការផ្គត់ផ្គង់និងសាងសង់បង្គន់អនាម័យ ចំនួន៩២បង្គន់ ស្ថិតក្នុងឃុំរក្សា ស្រុករវៀង។
- ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០១៦ ចូលរួមប្រជុំប្រចាំត្រីមាសជាអង្គការដៃគូរ និងបណ្តាអង្គភាព-មន្ទីរពាក់ព័ន្ធលើការងារទឹកស្អាត និងអនាម័យ នៅសាលប្រជុំមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ។
- ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០១៦ ចូលរួមប្រជុំប្រចាំត្រីមាសជាអង្គការដៃគូរ និងបណ្តាអង្គភាព-មន្ទីរពាក់ព័ន្ធ លើការងារទឹកស្អាត និងអនាម័យ នៅសាលប្រជុំមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ។

- ព្រឹកថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០១៦ ចូលរួមប្រជុំជាមួយក្រុមការងារពិសេសលុបបំបាត់ជម្ងឺគ្រុនចាញ់ ខេត្តព្រះវិហារក្រោមអធិបតីភាពឯកឧត្តម លី ដារារិទ្ធ អភិបាលរង នៃគណៈអភិបាលខេត្តព្រះវិហារ និងដោយមានការចូលរួមពីបណ្តាមន្ទីរ-វិស័យ និងអង្គការពាក់ព័ន្ធនៅសាលប្រជុំមន្ទីរសុខាភិបាលខេត្តព្រះវិហារ។
- បានជូនក្រុមសវនកម្មផ្ទៃក្នុងរបស់ក្រសួងអភិវឌ្ឍន៍ជនបទចុះពិនិត្យមើលបង្គន់អនាម័យថវិកាកម្មវិធីឆ្នាំ ២០១៥ ស្ថិតក្នុងឃុំថ្មី ស្រុកគូលែន និងឃុំរក្សា ស្រុករវៀង។
- បានជូនក្រុមសវនកម្មផ្ទៃក្នុងរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ចុះពិនិត្យមើលបង្គន់អនាម័យថវិកាកម្មវិធីឆ្នាំ ២០១៥ ស្ថិតក្នុងឃុំថ្មី ស្រុកគូលែន និងឃុំរក្សា ស្រុករវៀង។

5. **ការងារបណ្តុះបណ្តាល និង ស្រាវជ្រាវ ÷**
   - ថ្ងៃទី ២១-២២ ខែមករា ឆ្នាំ ២០១៦ ចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពី បញ្ហាការឆ្លើយតប និងការបន្សុំានឹងការប្រែប្រួលអាកាសធាតុ នៅខេត្តបាត់ដំបង។
   - ថ្ងៃទី ០២-០៥ ខែឧសភា ឆ្នាំ ២០១៦ ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីនិតិវិធីអនុវត្តថវិកាកម្មវិធី សម្រាប់អង្គភាពថវិកា សហការរៀបចំដោយវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅខេត្តសៀមរាប។

6. **ការងារអភិវឌ្ឍន៍សហគមន៍÷**
   - ថ្ងៃទី ២៦-២៨ ខែមករា ឆ្នាំ២០១៦ ចុះបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ឃុំរៀបរយ ស្រុករវៀង មានប០៣ ភូមិ គឺភូមិបង្កួនមានចំនួន ០៧ នាក់ ស្រី ចំនួន ០៣នាក់ ភូមិស្រែមានចំនួន ០៧នាក់ ស្រី ចំនួន ០៣នាក់ ភូមិ ស្លែងទោលចំនួន ០៧នាក់ស្រីចំនួន ០៣នាក់ មនុស្សសរុបចំនួន ២១ ស្រី ចំនួន ០៩នាក់
   - ថ្ងៃទី ២៩- ៣០ ខែមករា ឆ្នាំ ២១០១៦ ចុះបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ(គ.អ.ភ)ឃុំរហ័ស ស្រុករវៀង មាន០៦ភូមិ គឺ ភូមិអន្លង់ស្វាយ ចំនួន ០៧ នាក់ស្រីចំនួន ០៣នាក់ ភូមិកំពត ចំនួន ០៧នាក់ ស្រី ចំនួន ០៣ នាក់ ភូមិកក់ពោត ចំនួន ០៧នាក់ ស្រី ចំនួន ០២នាក់ ភូមិ ចម្លង ចំនួន០៧នាក់ ស្រី ចំនួន ០២នាក់ ភូមិ សង្លែង ចំនួន ០៧នាក់ ស្រីចំនួន ០៣នាក់ ភូមិ ថ្កែង ចំនួន ០៧នាក់ ស្រី ចំនួន ០២នាក់ មនុស្សសរុបចំនួន ៤២នាក់ ស្រីចំនួន ១៥នាក់ បូកសរុបរួម ០២ ឃុំ ០៩ភូមិ ចំនួនមនុស្ស ៦៣ នាក់ ស្រីចំនួន ២៤នាក់។
   - បានរៀបចំបំពេញបន្ថែមនូវសមាសភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ចំនួន ៣ឃុំ=១២ភូមិ រួមមាន ឃុំធ្នា= ៣ភូមិ= ២១នាក់ ឃុំប្រាច់= ៦ភូមិ= ៣៥នាក់ និង ឃុំពុទ្រា= ៣ភូមិ= ២៩នាក់ ក្នុងស្រុកជ័យសែន។

- ថ្ងៃទី ៣ ខែមិនា ឆ្នាំ២០១៦ ចុះបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ម្លូរព្រៃមួយ ស្រុកឆែប មាន០៣ ភូមិ គឺ ÷
    - ភូមិ កុល មានចំនួន ០៧ នាក់ ស្រី ចំនួន ០៣នាក់
    - ភូមិ ម្លូព្រៃ មានចំនួន ០៧ នាក់ ស្រី ចំនួន ០២នាក់
    - ភូមិ ពោធិទាបមានចំនួន ០៧ នាក់ ស្រី ចំនួន ០៤នាក់
- ថ្ងៃទី ០៤ ខែមិនា ឆ្នាំ២០១៦ ចុះបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ម្លូរព្រៃពីរ ស្រុកឆែប មាន០២ ភូមិ គឺ ÷
    - ភូមិ បុស្ស មានចំនួន ០៧ នាក់ ស្រី ចំនួន ០៣នាក់
    - ភូមិ ប្រើសក្អក មានចំនួន ១០ នាក់ ស្រី ចំនួន ០១នាក់
    - បូកសរុបរួម ០២ ឃុំ ០៥ ភូមិ ចំនួនមនុស្ស ៣៨ នាក់ ស្រីចំនួន ១៣នាក់
- ថ្ងៃទី ១៥ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៦ ចុះបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ឃុំប្រាច់ ស្រុកជ័យសែន មានចំនួន ០៦ ភូមិ =៤៧នាក់ ស្រីចំនួន ១២ នាក់។
- ថ្ងៃទី ១៦ ខែមិនា ឆ្នាំ២០១៦ ចុះបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ(គ.អ.ភ)ឃុំធ្នា ស្រុកជ័យសែន មានចំនួន ០៣ ភូមិ =២១នាក់ ស្រីចំនួន ០៧ នាក់។
- ថ្ងៃទី ១៧ ខែមិនា ឆ្នាំ២០១៦ ចុះបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ(គ.អ.ភ)ឃុំពុទ្រា ស្រុក ជ័យសែន មានចំនួន០៣ ភូមិ = ២៩ នាក់ ស្រីចំនួន ០៧ នាក់។
- ថ្ងៃទី ២៤ ខែមិនា ឆ្នាំ២០១៦ ចុះបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ(គ.អ.ភ)ឃុំ ពោធិ និងប្រមេរ ស្រុកត្បែងមានជ័យ មានចំនួន ០២ ភូមិ = ១៨ នាក់ ស្រីចំនួន ០៦ នាក់។
- បូកសរុបរួម ០២ស្រុក ០៥ ឃុំ ១៤ ភូមិ ចំនួនមនុស្ស ១១៥ នាក់ ស្រីចំនួន ៣២នាក់។
- ថ្ងៃទី ២៥-២៩ខែមេសា ឆ្នាំ ២០១៦ រៀបចំធ្វើផែនសកម្មភាពចុះពង្រឹងគណៈកម្មាធិការ អភិវឌ្ឍន៍ភូមិ
- ថ្ងៃទី ០៩-១០ ខែឧសភា ឆ្នាំ២០១៦ បានចុះបណ្តុះបណ្តាលដល់គណៈកម្មាធិការអភិវឌ្ឍន៍ ភូមិ ស្តីពីការកសាងផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ នៅឃុំចំរើន ស្រុកសង្គមថ្មី ដែលមាន អ្នកចូលរួមសរុប ៣៩នាក់ ស្រី២០នាក់ ដោយមានការចូលរួមគាំទ្រដោយអង្គការទស្សនៈ ពិភពលោកប្រចាំស្រុកសង្គមថ្មី។
- ថ្ងៃទី ១១-១២ ខែឧសភា ឆ្នាំ ២០១៦ បានចុះបណ្តុះបណ្តាលដល់គណៈកម្មាធិការ អភិវឌ្ឍន៍ភូមិ ស្តីពីការកសាងផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ នៅឃុំរំដោះ ស្រុករវៀង

ដែលមានអ្នកចូលរួមសរុប ៣៩នាក់ ស្រី ២២នាក់ ដោយមានការចូលរួមគាំទ្រដោយអង្គការទស្សនៈពិភពលោកប្រចាំស្រុកសង្គមថ្មី។

- ថ្ងៃទី ១៦-១៧ ខែឧសភា ឆ្នាំ ២០១៦ បានចុះបណ្តុះបណ្តាលដល់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ស្តីពីការកសាងផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ នៅឃុំរអាង ស្រុកសង្គមថ្មី ដែលមានអ្នកចូលរួមសរុប ៣៦នាក់ ស្រី១៥នាក់ ដោយមានការចូលរួមគាំទ្រ ដោយអង្គការទស្សនៈពិភពលោកប្រចាំស្រុកសង្គមថ្មី។
- ថ្ងៃទី ១៨-១៩ ខែឧសភា ឆ្នាំ២០១៦ បានចុះបណ្តុះបណ្តាលដល់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ស្តីពីការកសាងផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ នៅឃុំភ្នំត្បែង១ ស្រុកសង្គមថ្មី ដែលមានអ្នកចូលរួមសរុប ១៨នាក់ ស្រី០៨នាក់ ដោយមានការចូលរួមគាំទ្រដោយអង្គការទស្សនៈពិភពលោកប្រចាំស្រុកសង្គមថ្មី។
- ថ្ងៃទី ១៦-១៧ ខែឧសភា ឆ្នាំ ២០១៦ បានចុះបណ្តុះបណ្តាលដល់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ស្តីពីការកសាងផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ នៅឃុំរអាង ស្រុកសង្គមថ្មី ដែលមានអ្នកចូលរួមសរុប ៣៦នាក់ ស្រី ១៥នាក់ ដោយមានការចូលរួមគាំទ្រ ដោយអង្គការទស្សនៈពិភពលោកប្រចាំស្រុកសង្គមថ្មី។
- ថ្ងៃទី ១៨-១៩ ខែឧសភា ឆ្នាំ ២០១៦ បានចុះបណ្តុះបណ្តាល ដល់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ស្តីពីការកសាងផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ នៅឃុំភ្នំត្បែង១ ស្រុកសង្គមថ្មី ដែលមានអ្នកចូលរួមសរុប ១៨នាក់ ស្រី ០៨នាក់ ដោយមានការចូលរួមគាំទ្រដោយអង្គការទស្សនៈពិភពលោកប្រចាំស្រុកសង្គមថ្មី។
- ថ្ងៃទី ២៥-២៦ ខែឧសភា ឆ្នាំ ២០១៦ ចុះបើកវគ្គបណ្តុះបណ្តាលពង្រឹងសម្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅឃុំស្ដៅ ស្រុក សង្គមថ្មី ខេត្តព្រះវិហារ មានចំនួន០៥គឺ ភូមិសុច ភូមិស្ដៅ ភូមិ ត្រពាំងខ្នែង ភូមិត្រពាំងធ្លក និងភូមិតាបស់ សមាសភាពចូលរួមមាន ចំនួន ៣៥ នាក់ ស្រី ១៥នាក់។
- ថ្ងៃទី ២៧-២៨ ខែឧសភា ឆ្នាំ ២០១៦ ចុះបើកវគ្គបណ្តុះបណ្តាលពង្រឹងសម្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅឃុំរណសិរ្ស ស្រុក សង្គមថ្មី ខេត្តព្រះវិហារ មានចំនួន ០៦ គឺ ភូមិសុច ភូមិតាសែងកណ្តាល ភូមិតាសែងជើង ភូមិស្វាយ ត្រពាំងរាំង រលំឡែង និងភូមិគោកថ្កូវ សមាសភាពចូលរួមមាន ចំនួន ៤១ នាក់ ស្រី ១០ នាក់។

7. **ការងារសេដ្ឋកិច្ចជនបទ៖**

   - គ្មានសកម្មភាព។

8. **ការងារជនជាតិដើមភាគតិច៖**

- នៅថ្ងៃច័ន្ទ ទី ១៣ ខែមិថុនា ឆ្នាំ ២០១៦ ចូលរួមប្រជុំពិភាក្សាពិគ្រោះយោបល់ ស្តីពី គោលការណ៍ បង្កើតក្រុមការងារតំណាងជនជាតិភាគតិចនៅតាមខេត្ត ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី អ៊ុក រ៉ាប៊ុន** នៅសាលប្រជុំជាន់ទី ៣ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ។

9. **ការងារយេនឌ័រ÷**

- ថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០១៦ បានចូលរួមអបអរសាទរទិវាអន្តរជាតិ ០៨ មីនា ឆ្នាំ២០១៦ ខួបលើកទី ១០៥ នៅក្រសួងអភិវឌ្ឍន៍ជនបទរាជធានីភ្នំពេញ ។

10. **គម្រោង / កម្មវិធី ÷**

10.1. **កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ នៅតាមសាលារៀន និងសហគមន៍** (**គាំទ្រថវិកាដោយ** UNICEF)

- ថ្ងៃទី ២២-២៤ ខែធ្នូ ឆ្នាំ២០១៥ ក្រុមការងារទឹកស្អាត និងអនាម័យបានចុះទៅបញ្ចាំងវីដេអូឃ្លីប ស្តីពីការលើកកម្ពស់ការប្រើប្រាស់ទឹកស្អាត និងអនាម័យរបស់ប្រជាពលរដ្ឋ នៅភូមិដូនម៉ា,កក់ពោន និងស្រឡៅស្រោង ស្ថិតក្នុងឃុំរក្សា ស្រុករវៀង។
- ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ ក្រុមការងារទឹកស្អាត និងអនាម័យបានចុះពិនិត្យ និងជំរុញបំផុសតាមខ្នងផ្ទះស្តីពីការសាងសង់និងប្រើប្រាស់បង្គន់ ការទុកដាក់ទឹកហូប និងប្រើប្រាស់ និងការសម្អាតបរិស្ថានជុំវិញផ្ទះរបស់ប្រជាពលរដ្ឋនៅភូមិត្រាវគៀត ស្ទឹងសែនមនោរម្យ ថ្នល់បែក និងភូមិពង្រ ស្ថិតក្នុងឃុំថ្មី ស្រុកគូលែន ដោយបានសហការជាមួយអភិបាលរងស្រុកគូលែន គ.ក.ន.ក ឃុំថ្មី និងជនបង្គោលតាមភូមិនីមួយៗ។
- ក្រុមការងារទឹកស្អាត និងអនាម័យជនបទ បានចុះជំរុញ និងលើកទឹកចិត្ត ដល់ប្រជាពលរដ្ឋ ដែលមិនទាន់បានសាងសង់បង្គន់ អោយគាត់បានចូលរួមសាងសង់ និងប្រើប្រាស់ នៅតាមភូមិគោលដៅទាំង ១៦ភូមិ ដោយបានជំរុញឲ្យគាត់សាងសង់ និងប្រើប្រាស់បង្គន់អនាម័យគ្រួសារ។
- សម្របសម្រួលកិច្ចប្រជុំប្រចាំត្រីមាសទី៤ ឆ្នាំ២០១៥ លើការងារទឹកស្អាត និងអនាម័យជនបទ។
- ក្រុមការងារទឹកស្អាត និងអនាម័យជនបទ បានចុះជំរុញ បំផុស និងលើកទឹកចិត្តដល់ប្រជាពលរដ្ឋ ដែលមិនទាន់បានសាងសង់បង្គន់ អោយគាត់បានចូលរួមក្នុងការសាងសង់ និងប្រើប្រាស់បង្គន់អនាម័យជាលក្ខណៈគ្រួសារ នៅតាមភូមិគោលដៅទាំង១៦ភូមិ= ៣ឃុំ។

- បានដឹកនាំទិវាអនាម័យសម្អាតភូមិ និងបរិវេណជុំវិញផ្ទះរបស់ប្រជាពលរដ្ឋនៅឃុំរក្សា ០៨ភូមិ អ្នកចូលរួមសរុប ២៩៥នាក់ ក្នុងនោះស្រី ២០១នាក់ និងឃុំថ្មី ០៦ភូមិ ៣១២នាក់ ស្រី ២២៣នាក់។
- ក្រុមការងារទឹកស្អាត និងអនាម័យជនបទ បានចុះជំរុញ បំផុស និងលើកទឹកចិត្តដល់ប្រជាពលរដ្ឋ ដែលមិនទាន់បានសាងសង់បង្គន់ អោយគាត់បានចូលរួមក្នុងការសាងសង់ និងប្រើប្រាស់បង្គន់អនាម័យជាលក្ខណៈគ្រួសារ នៅតាមភូមិគោលដៅទាំង១៦ភូមិ= ៣ឃុំ។
- បានដឹកនាំទិវាអនាម័យសម្អាតភូមិ និងបរិវេណជុំវិញផ្ទះរបស់ប្រជាពលរដ្ឋនៅឃុំរក្សា ០៨ភូមិ អ្នកចូលរួមសរុប ២៩៥នាក់ ក្នុងនោះស្រី ២០១នាក់ និងឃុំថ្មី ០៦ភូមិ ៣១២នាក់ ស្រី ២២៣នាក់។
- បានធ្វើឯកសារទូទាត់ត្រីមាសទី៤ ឆ្នាំ២០១៥
- បានធ្វើសំណើសុំថវិកាសម្រាប់ត្រីមាសទី២ឆ្នាំ២០១៦។
- ថ្ងៃទី ៧-១០ ខែមិថុនា ឆ្នាំ ២០១៦ បានចូលរួមក្នុងវគ្គកសាងសមត្ថភាពមន្ត្រីបច្ចេកទេសស្តីពីការអនុវត្តកម្មវិធីសហគមន៍ដឹកនាំអនុវត្តអនាម័យ រៀបចំដោយនាយកដ្ឋានថែទាំសុខភាពជនបទ និងមានការគាំទ្រថវិកាដោយអង្គការយូនីសេហ្វ នៅសាលប្រជុំ សាខាកាកបាទក្រហមខេត្តព្រះវិហារ អ្នកចូលរួមសរុបប្រមាណ៤២នាក់ ក្នុងនោះស្រី១២នាក់ មកពីតាមបណ្តាខេត្តទាំង ៥ គឺព្រះវិហារ ស្ទឹងត្រែង រតនគីរី ក្រចេះ និងមណ្ឌលគីរី។

10.2. **ការងារគាំទ្រដោយ** NGOs

- ថ្ងៃទី ១១ ខែមករា ឆ្នាំ២០១៦ បានចុះធ្វើការងារទឹកស្អាតជាមួយថ្នាក់ដឹកនាំភូមិឃុំ និងគណៈកម្មការទឹកស្អាត នៅភូមិពង្រ ឃុំថ្មី ស្រុកគូលែន លើការងារផែនការតបណ្តាញទឹកស្អាតតាមខ្នងផ្ទះរបស់ប្រជាពលរដ្ឋ
- ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៦ បានសម្របសម្រួលកិច្ចប្រជុំស្តីពីកិច្ចពិគ្រោះយោបល់ជាមួយសហគមន៍ភូមិពង្រ ឃុំថ្មី ស្រុកគូលែន អំពីផែនការលម្អិតសម្រាប់សម្ភារៈតបណ្តាញទឹកស្អាតទៅតាមខ្នងផ្ទះ
- ថ្ងៃទី២១-២២ និង២៥-២៦ ខែមករា ឆ្នាំ២០១៦ បានចូលរួមពិនិត្យអណ្តូងស្នប់ចំនួន៥អណ្តូងដែលមានបញ្ហា ស្ថិតនៅស្រុកគូលែន និងស្រុករវៀង ជាតំបន់គោលដៅរបស់កាកបាតក្រហមខេត្តព្រះវិហារក្រោមការគាំទ្រពីកាកបាតក្រហមដាណឺម៉ាក
- ថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១៦ បានសហការជាមួយអង្គការទស្សនៈពិភពលោកស្រុកសង្គមថ្មីដើម្បីចុះពិនិត្យទីតាំងប្រភពទឹក ក្នុងការរៀបចំផែនការសម្រាប់ពេលខាងមុខ

- ថ្ងៃទី២៤-២៥ ខែមករា ឆ្នាំ២០១៦ មន្ទីរបានសហការជាមួយការិយាល័យអប់រំយុវជន និងកីឡាស្រុកសង្គមថ្មី ក្រោមការឧបត្ថម្ភពីអង្គការទស្សនៈពិភពលោកស្រុកសង្គមថ្មី បានបើកវគ្គបណ្តុះបណ្តាលស្តីពីកម្មវិធីលើកកម្ពស់ទឹកស្អាត និងអនាម័យតាមសាលារៀន ជូនដល់លោកគ្រូអ្នកគ្រូមកពីគ្រឹះស្ថានសិក្សាទាំង២កម្រិត រួមមានកម្រិតអនុវិទ្យាល័យ និងបឋមសិក្សាទាំង ៨សាលាគោលដៅ សរុបអ្នកចូលរួម៣៩នាក់ ស្រី១៩នាក់។
- ព្រឹកថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ចូលរួមប្រជុំពិភាក្សាការងារជាមួយអង្គការ វីនរ៉កកម្ពុជាក្រោមអធិបតីភាព ឯកឧត្តម **សុខ ហៃ** អភិបាលរងនៃគណអភិបាលខេត្តព្រះវិហារ នៅសាលប្រជុំ Video Conference អាគាររដ្ឋបាលសាលាខេត្តជាន់ទី១។
- ថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១៦ ចូលរួមសិក្ខាសាលាស្តីអំពីការពិគ្រោះយោបល់ និងបង្ហាញលទ្ធផលស្ទាបស្ទង់ ជំហានដំបូង សមត្ថភាពបន្សុំាបម្រែបម្រួលអាកាសធាតុក្នុងស្រុកជាំក្សាន្ត ក្រោមការសម្របសម្រួលរបស់ អង្គការ Action Hunger ដោយមានការចូលរួមពីមន្ទីរ-ពាក់ព័ន្ធ អាជ្ញាធរស្រុក ឃុំ ភូមិ នៅមន្ទីរបរិស្ថានខេត្ត ព្រះវិហារ។
- ថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០១៦ ចូលរួមសិក្ខាសាលាស្តីអំពីការវិភាគរកមូលហេតុ នៃកង្វះអាហារូបត្ថម្ភ រៀបចំដោយអង្គការ ACF នៅរាជធានីភ្នំពេញ។
- ថ្ងៃទី ០៩ ខែឧសភា ឆ្នាំ ២០១៦ ចូលរួមប្រជុំវាយតម្លៃបញ្ចប់គម្រោង នៃអង្គការទស្សនពិភពលោក ប្រចាំស្រុកជ័យសែនរយៈពេល០៤ឆ្នាំកន្លង ដែលបានសហការជាមួយមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ ក្រោមអធិតីភាព លោក សេង សារី ប្រធានមន្ទីរ និងបុគ្គលិកអង្គការទស្សនៈពិភពលោកប្រចាំស្រុកជ័យសែន ចំនួន៣នាក់ ស្រី១នាក់ នៅសាលប្រជុំរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ។
- ថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០១៦ ចូលរួមប្រជុំពិភាក្សាលើកម្មវិធីទឹកស្អាតនិងអនាម័យជាមួយអង្គការ ACTION AGAINST HUNGER ប្រចាំខេត្តព្រះវិហារ ក្រោមអធិតីភាព លោក សេង សារី ប្រធានមន្ទីរអភិវឌ្ឍន៍ ជនបទខេត្តដែលមានអ្នកចូរួមសរុបចំនួន០៥នាក់ នៅសាលប្រជុំរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ។
- រសៀលថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០១៦ ចូលរួមប្រជុំពិភាក្សាអំពីការស្នើសុំការគាំទ្រក្នុងការឆ្លើយតប ទៅនឹងបញ្ហាកង្វះអាហារូបត្ថម្ភរវាងតំណាងយុវជនខេត្តព្រះវិហារ ដែលគាំទ្រដោយអង្គការទស្សនៈពិភព លោកប្រចាំខេត្តព្រះវិហារក្រោមអធិបតីភាព ឯកឧត្តម អ៊ុំ ម៉ារ៉ា អភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ នៅសាលប្រជុំ VIDEO CONFERENT សាលាខេត្តព្រះវិហារ។

- នៅថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០១៦ បានចូលរួមប្រជុំស្ដីពីកម្មវិធីទឹកស្អាតជាមួយអង្គការ ACTION AGAINST HUNGER ប្រចាំខេត្តព្រះវិហារ។
- នៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០១៦ ចុះវាស់ស្រះសហគមន៍ នៅភូមិកំពេញ ឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។
- នៅថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០១៦ បានចូលរួមប្រជុំស្ដីពីកម្មវិធីទឹកស្អាតជាមួយអង្គការ ACTION AGAINST HUNGER ប្រចាំខេត្តព្រះវិហារ។
- នៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០១៦ ចុះវាស់ស្រះសហគមន៍ នៅភូមិកំពេញ ឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។
- ថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០១៦ បានចូលរួមប្រជុំពិភាក្សាជាមួយអង្គការ ACTION AGAINST HUNGER ពាក់ព័ន្ធលើការប្រើប្រាស់ទឹកស្អាត និង អនាម័យ នៅសាលប្រជុំមន្ទីរអភិវឌ្ឍន៍ជនបទ។
- នៅថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០១៦ ប្រជុំគណៈកម្មការសម្របសម្រួលគម្រោង រៀបចំដោយ ADDRA មានការចូលរួមពីមន្ទីរវិស័យពាក់ព័ន្ធគម្រោងខេត្តកំពង់ធំ ព្រះវិហារ ស្រុក ឃុំ នៅសាលប្រជុំនៅសាលប្រជុំមន្ទីរសុខាភិបាលខេត្តព្រះវិហារ។
- នៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៦ មន្ត្រីជំនាញផ្គត់ផ្គង់ទឹកជនបទ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ គម្រោងលើកកម្ពស់ជីវភាព របស់ប្រជាពលរដ្ឋនៅជនបទ របស់អង្គការ CWS នៅសាលប្រជុំកបាត ក្រហម ប្រចាំខេត្តព្រះវិហារ។
- ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៦ បានចូលរួមក្នុងសិក្ខាសាលាផ្សព្វផ្សាយពីគម្រោង “លើកកម្ពស់ជីវភាពប្រជាពលរដ្ឋកម្ពុជានៅជនបទ” នៅសាលប្រជុំសាខាកាកបាទក្រហមខេត្តព្រះវិហារ រៀបចំដោយអង្គការ ស៊ីដាប់បែលយូអេស។
- នៅថ្ងៃទី ១១-១២ ខែមិថុនា ឆ្នាំ ២០១៦ បានជួសជុលអណ្ដូងបានចំនួន០៨អណ្ដូង (ឃុំគូលែនជើងបាន ៥អណ្ដូង និងគូលែនត្បូងបាន ៣អណ្ដូងស្ទះ)ដែលសហការជាមួយអង្គការទស្សនៈពិភពលោកស្រុកគូលែន។
- នៅថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០១៦ មន្ត្រីជំនាញផ្គត់ផ្គង់ទឹកជនបទ បានចូលរួមប្រជុំពិភាក្សាជាមួយអង្គការ ACTION AGAINST HUNGER ការចុះវាស់វែងស្រះ នៅឃុំយាង និងឃុំកន្ទួត នៅទីរួមខេត្តព្រះវិហារ៕